រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៧

# របាយការណ៍សង្ខេប
# ស្តីអំពី
# ការផ្ទៀងផ្ទាត់លើលទ្ធផលបោះឆ្នោតបឋម
# នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៤

សមាគម អង្គការសង្គមស៊ីវិលនៃបន្ទប់ស្ថានការណ៍ ស្តីពីការបោះឆ្នោតឆ្នាំ២០១៧ បានធ្វើការផ្ទៀងផ្ទាត់ទិន្នន័យ និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (១១០២) ដែលផ្សាយក្នុងគេហទំព័ររបស់ គ.ជ.ប ក្រោយពេលបោះឆ្នោត ជាមួយនឹងកំណត់នៃការរាប់សន្លឹកឆ្នោត (១១០២) ដែលប្រមូលបានដោយបន្ទប់ស្ថានការណ៍។ កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (១១០២) ដែលប្រមូលបានដោយបន្ទប់ស្ថានការណ៍ចំនួន ៤៨១ការិយាល័យបោះឆ្នោតដែលជាការិយាល័យសំណាក ក្នុងកំរិតជឿជាក់ ៩៥% ជាមួយកំរិតលំអៀង ៤.៣% ត្រូវបានជ្រើសរើសដោយចៃដន្យ(Sample Random) និងយកមកផ្ទៀងផ្ទាត់ ហើយរកឃើញ ចំណុចមួយចំនួនដូចខាងក្រោម៖

១. បើទោះបីជា គ.ជ.ប បានចេញផ្សាយចំនួន០២លើក អំពីអត្រានៃចំនួនបណ្តោះអាសន្ននៃអ្នកបានទៅបោះឆ្នោត លើកទី១ នៅថ្ងៃទី០៤ ខែមិថុនា ២០១៧ គឺមានចំនួន ៨៥,៧៤% (ស្មើប្រមាណ ៦,៧លាននាក់) និងលើកទី២ នៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ ២០១៧ គឺមានចំនួន ៨៩,៥២% (ស្មើប្រមាណ ៧លាននាក់)។ ការផ្ទៀងផ្ទាត់ទិន្នន័យដែលប្រមូលបានដោយបន្ទប់ស្ថានការណ៍រកឃើញថា អត្រានៃចំនួននៃអ្នកបោះឆ្នោតបានទៅបោះឆ្នោតមានចំនួន ៨៩,៩% នៃប្រជាពលរដ្ឋមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតនៃការិយាល័យសំណាក។

២. ការសង្កេត និងការផ្ទៀងផ្ទាត់របស់បន្ទប់ស្ថានការណ៍ រកឃើញទំហំ «សន្លឹកឆ្នោតមិនបានការ» នៅក្នុងដំណើរការរាប់សន្លឹកឆ្នោតមានចំនួន ១,៨% នៃសន្លឹកឆ្នោតដែលមានក្នុងហិបសរុប។ ការកំណត់សន្លឹកឆ្នោតមិនបានការ អាចក្លាយជាភាពមិនប្រក្រតី ដូចជាករណីខ្លះ ការកំណត់សន្លឹកឆ្នោតមិនបានការមានចំនួនច្រើនពេក ហើយមិនស្របតាមការណែនាំរបស់ គ.ជ.ប ដូចជានៅការិយាល័យ<u>០០១៦ ឃុំសាមឃ្យួយ</u> ខេត្តស្ទឹងត្រែង ឃុំភ្នំលៀប ខេត្តបន្ទាយមានជ័យ ឃុំឫស្សីស្រុក ខេត្តសៀមរាប និងកន្លែងផ្សេងទៀត។ ករណីនេះអាចប៉ះពាល់លទ្ធផលបោះឆ្នោតបឋម ដែលនាំឱ្យមានបណ្តឹងនៃរាប់សន្លឹកឆ្នោតឡើងវិញចំនួន២៨នៅ៤៧ការិយាល័យតាមសេចក្តីប្រកាសព័ត៌មានរបស់ គ.ជ.ប នៅថ្ងៃទី០៦ ខែមិថុនា។

៣. ការផ្ទៀងផ្ទាត់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត(១១០២)៖

៣.១. ការផ្ទៀងផ្ទាត់ទិន្នន័យនៃកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (១១០២) ប្រមូលដោយបន្ទប់ស្ថានការណ៍ ជាមួយនឹងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (១១០២) ដែលបានផ្សាយក្នុងគេហទំព័ររបស់ គ.ជ.ប មានភាពត្រឹមត្រូវដូចគ្នានឹងកំណត់ហេតុដែលប្រមូលដោយបន្ទប់ស្ថានការណ៍មានចំនួន ៨៨,១% នៃទម្រង់ការិយាល័យសំណាក(ខុសគ្នា ១១.៩%)។ ទោះជាយ៉ាងណា លទ្ធផលនៃការរាប់សន្លឹកឆ្នោតសម្រាប់គណបក្សនយោបាយនិមួយៗតាមការិយាល័យ

រាប់សន្លឹកឆ្នោត[1] ខុសគ្នាចំនួន ៦,៩% (ចំនួន ៩៣,១% ដូចគ្នា) ដែលទាក់ទិនការបំពេញសន្លឹកឆ្នោតបានការ ឬមិនបានការ ហើយខ្លះទៀតបូកលេខខុសតែម្តងដោយសារតែភាពធ្វេសប្រហែស[2]។ រីឯលទ្ធផលនៃការផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោត តាមការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត[3] រកឃើញថា ៩៣,៦% ដូចគ្នា (៦,៤% រកឃើញថាមានតួលេខខុសគ្នា)។ ការខុសគ្នាអាចកើតឡើងដោយការធ្វេសប្រហែស ឬការមិនយល់ក្នុងការគណនា និងកត់ត្រា (វាអាចបណ្តាលមកពីមន្ត្រីចម្លងច្រើនសន្លឹក និងមិនប្រើក្រដាសកាល់)[4]។ សាក្សីដែលជាភ្នាក់ងារគណបក្សនយោបាយ រកឃើញថា ១,៧% ខុសគ្នាត្រង់សាក្សីនៃភ្នាក់ងារទម្រង់ខ្លះមិនចុះហត្ថលេខា[5]។

៣.២. ការផ្ទៀងផ្ទាត់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (១១០២) ដែលមានភាពមិនប្រក្រតី ប្រមូលដោយអ្នកសង្កេតការណ៍បន្ទប់ស្ថានការណ៍ ជាមួយនឹងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (១១០២) ដែលផ្សាយក្នុងគេហទំព័ររបស់ គ.ជ.ប រកឃើញថា ក្នុងចំណោម ៣០ទំរង់ ទ.១១០២ មានតែមួយទំរង់ទេ ដែលមានភាពមិនប្រក្រតីដូចគ្នា ហើយ ២៩ទំរង់ទៀតរបស់ គ.ជ.ប គឺមានភាពត្រឹមត្រូវ[6]។ ភាពមិនប្រក្រតីទាំងនោះ មានដូចជា៖ ការបិទប្រកាសដោយមិនបានកត់ត្រាសំឡេងឆ្នោតរបស់គណបក្សនយោបាយ នៅការិយាល័យ <u>០១៥៥ ខេត្តរតនៈគិរី</u> ការសរសេរឈ្មោះបេក្ខជនក្នុងសំឡេងគណបក្សនយោបាយ (<u>ការិ.០៤៩៥ នៅខេត្តកំពង់ចាម</u>) ការមិនបំពេញឈ្មោះគណបក្សនយោបាយ(<u>ការិ.០០៦៣ ខេត្តកំពង់ឆ្នាំង</u>) ការមិនបំពេញតួលេខឱ្យបានត្រឹមត្រូវក្នុងចំណុចសន្លឹកឆ្នោតបានការ និងមិនបានការ ចំនួនសន្លឹកឆ្នោតសរុបមិនស្មើគ្នា មានតួលេខលើស និងខ្វះ ឬច្រឡំកន្លែងដែលត្រូវចុះរវាងសន្លឹកឆ្នោតខូច ជាមួយសន្លឹកឆ្នោតមិនបានការ កន្លែងខ្លះមានប្រើទឹកលុប ការគូសសញ្ញាបញ្ជាក់លើចំណុចផ្សេងៗជាដើម។

៤. ការផ្ទៀងផ្ទាត់លើលទ្ធផលបឋមនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (១១០៥)

លទ្ធផលបោះឆ្នោតបឋមនៅតាមឃុំសង្កាត់ ដែលបានមកពីការបូកសំឡេងឆ្នោតរបស់គណបក្សនៃកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (១១០២) ដែលប្រមូលដោយបន្ទប់ស្ថានការ ហើយយកទៅផ្ទៀងផ្ទាត់ជាមួយកំណត់ហេតុ ១១០៥ របស់គ.ជ.ប ចំនួន៣០ឃុំ រកឃើញថា មានមួយករណីនៅឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ក្នុងការិយាល័យ ០៣០៤ មានសន្លឹកឆ្នោតរបស់គណបក្សនយោបាយខុសគ្នារវាង <u>គ.ជ.ប</u> និងក្នុងកំណត់ហេតុលទ្ធផលឆ្នោត(១១០២) ដែលបានប្រមូលដោយ<u>បន្ទប់ស្ថានការណ៍</u> នៃលទ្ធផលបឋមនៃការបោះឆ្នោតក្នុងឃុំ សង្កាត់[7] ។ បើទោះបីមានកំហុសខ្លះ នៃលទ្ធផលបឋមដែលកំពុងត្រួតពិនិត្យ គ.ជ.ប អាចមានលទ្ធភាពកែតម្រូវភ្លាមៗ។ ការសង្កេតរកឃើញថាលទ្ធផលបឋម(កំពុងត្រួតពិនិត្យ)យ៉ាងហោចខុសពីរឃុំ បើផ្ទៀងផ្ទាត់កំណត់ហេតុ ទ.១១០២ និង ១១០៥។

៥. បញ្ហាផ្សេងៗ៖

៥.១. ការមិនបិទផ្សាយការប្រកាសកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (១១០២) នៅតាមគណៈកម្មការឃុំ/សង្កាត់រៀបចំការបោះឆ្នោតជាច្រើនឃុំ/សង្កាត់ ដូចជា៖ ខេត្តត្បូងឃ្មុំ ឃុំជីរោទិ៍១ ក្នុងទីតាំងការិយាល័យ បឋមសិក្សាហ៊ុនសែនរកាធំ ០៩៩០ ០៩៩៥ ០៩៨៩ ខេត្តបាត់ដំបង សង្កាត់ព្រែកព្រះស្តេច ខេត្តបន្ទាយមានជ័យ ឃុំបន្ទាយឆ្មារ ការិយាល័យ

---

1 ចំណុចទី៤ នៃកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (១១០២)

2 រកឃើញតែមួយករណី (ទ.១១០២ខុមប្រែ្វល) ខ្វះសំឡេងគណបក្សហ៊្វុនស៊ិនប៉ិច នៅក្នុងការិយាល័យ ០៨៨៥ខេត្តកំពង់ចាម។

3 ចំណុចទី២ នៃកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (១១០២)

4 ដូចជាការិយាល័យ ០៣៧០ និង១២៧១ ក្នុងខេត្តកំពង់ចាម និងការិយាល័យផ្សេងទៀត។

5 ដូចជាការិយាល័យ ០៦៥៣ ខេត្តកំពង់ឆ្នាំង ការិយាល័យ ០៨៦០ ខេត្តតាកែវជាដើម។

6 ទម្រង់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត(ទ.១១០២)ចំនួន៣០ ដូចគ្នាតែ១ជាមួយ គ.ជ.ប

7 ចំណុចទី៤ នៃលទ្ធផលបឋមនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (១១០៥)

០៧៧៦(សូម្បីគណបក្សនយោបាយក៏មិនចែកឱ្យគេដែរ) ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង និងខេត្តរតនគិរី អត់មានបិទនៅ គឃ.សប ស្ទើគ្រប់ទីកន្លែង ដោយប្រធាន គឃ.សប ថាមិនមានការណែនាំ ឬមិនតម្រូវឱ្យបិទ ទោះបីចែងនៅក្នុងចំណុច ១០.៤.៣.១ នៃបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ប.ន.ឃ.ស) ក៏ដោយ។

៥.២. ការប្រកាសលទ្ធផលបោះឆ្នោតបឋមដោយ គ.ជ.ប យឺតជាងការគ្រោងទុក។ ការផ្សាយលទ្ធផលបោះឆ្នោតបឋមតាម វិទ្យុ យៈទូរទស្សន៍ជាតិកម្ពុជា (ទទក) ពិបាកយល់ និងមិនបានពេញលេញ។ ការផ្សាយលទ្ធផលបោះឆ្នោតបឋមបានតែ ចំនួន៦១៦ឃុំ/សង្កាត់ ហើយមិនត្រូវបានផ្សាយបន្តទៀត ចាប់ពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៧។

៥.៣. បណ្តឹងទាក់ទងការរាប់សន្លឹកឆ្នោតឡើងវិញមានចំនួន២៨បណ្តឹង ដោយសារកំរិតលំអៀងនៃសំឡេងឆ្នោតរបស់គណបក្សពីរមានចំនួនតិចតួច ប៉ុន្តែសន្លឹកឆ្នោតមិនបានការនៃការិយាល័យនោះមានចំនួនច្រើនជាងសំឡេងលំអៀងនោះ។ ការរាប់សន្លឹកឆ្នោតឡើងវិញបានធ្វើឲ្យប្រែប្រួលលទ្ធផលបឋមនៃការបោះឆ្នោតនៃឃុំ សង្កាត់ចំនួនបួន។

សេចក្តីសន្និដ្ឋាន កំណត់ហេតុ នៃការរាប់សន្លឹកឆ្នោត (១១០២) ដែលប្រមូលដោយបន្ទប់ស្ថានការ និងផ្សាយដោយ គ.ជ.ប ត្រឹមត្រូវដូចគ្នា ៩៣,១%នៃលទ្ធផលនៃការរាប់សន្លឹកឆ្នោតសម្រាប់គណបក្សនយោបាយ[8] និង ៩៣,៦% នៃលទ្ធផលនៃការផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោត[9]។ ការខុសគ្នា និងភាពមិនប្រក្រតីនៃកំណត់ហេតុ១១០២ មិនអាចនាំឲ្យមានការសង្ស័យប៉ះពាល់លទ្ធផលបោះឆ្នោតបឋមនោះទេ។

**ព័ត៌មានបន្ថែមសូមទាក់ទង៖**


| | | | |
|---|---|---|---|
| 1. | លោក គល់ បញ្ញា | នាយកប្រតិបត្តិ COMFREL | ០១២ ៩៤ ២០ ១៧ |
| 2. | លោក កន សាវាង្ស | អ្នកសម្របសម្រួលផ្នែកអង្កេត COMFREL | ០១១ ៨៨ ៤៨ ៤០ |
| 3. | លោក យឿង សុធារ៉ា | មន្ត្រីច្បាប់ និងអង្កេត COMFREL | ០៧០ ៤០ ០១ ៣១ |


[8] ចំណុចទី៤ នៃកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (១១០២)

[9] ចំណុចទី២ នៃកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (១១០២)